ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ: ៦៦៦៥ សសរ

2024-117
01.11.24

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតគណៈបញ្ជាការដឹកនាំស្រាវជ្រាវ ស៊ើបអង្កេត និងបង្ក្រាបបទល្មើសគ្រប់ប្រភេទ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកម/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណូមពរចាំបាច់នៃការងារ

## សម្រេច

**ប្រការ១ ._**

ត្រូវបានបង្កើតគណៈបញ្ជាការដឹកនាំស្រាវជ្រាវ ស៊ើបអង្កេត និងបង្ក្រាបបទល្មើសគ្រប់ប្រភេទ ដែលមានសមាសភាពដូចខាងក្រោម ៖

| | | | |
|---|---|---|---|
| ១- | ឯកឧត្តម នាយឧត្តមសេនីយ៍ **ស ថេត** | អគ្គស្នងការ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ | ប្រធាន |
| ២- | ឯកឧត្តម ឧត្តមសេនីយ៍ឯក **សុខ វាសនា** | អគ្គនាយកនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ | អនុប្រធាន |
| ៣- | **អភិបាល នៃគណៈអភិបាលរាជធានី ខេត្ត** | | អនុប្រធាន |
| ៤- | ឯកឧត្តម ឧត្តមសេនីយ៍ឯក **ឌី វិជ្ជា** | អគ្គស្នងការរងនគរបាលជាតិ | អនុប្រធានអចិន្ត្រៃយ៍ |

| | | | |
|---|---|---|---|
| ៥- ឯកឧត្តម ឧត្តមសេនីយ៍ឯក | **ឃឹម លាច** | អគ្គស្នងការរងនគរបាលជាតិ | សមាជិក |
| ៦- ឯកឧត្តម ឧត្តមសេនីយ៍ឯក | **មួច សុធា** | អគ្គស្នងការរងនគរបាលជាតិ | សមាជិក |
| ៧- ឯកឧត្តម ឧត្តមសេនីយ៍ឯក | **ជីវ ផល្លី** | អគ្គស្នងការរងនគរបាលជាតិ | សមាជិក |
| ៨- ឯកឧត្តម ឧត្តមសេនីយ៍ឯក | **ជា ពៅ** | អគ្គស្នងការរងនគរបាលជាតិ | សមាជិក |
| ៩- ឯកឧត្តម ឧត្តមសេនីយ៍ឯក | **ជួន ណារិន្ទ** | អគ្គស្នងការរង និងជាស្នងការនៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ | សមាជិក |
| ១០- ឯកឧត្តម ឧត្តមសេនីយ៍ឯក | **ស រដ្ឋា** | អគ្គស្នងការរង និងជាស្នងការនៃស្នងការដ្ឋាននគរបាលខេត្តព្រះសីហនុ | សមាជិក |
| ១១- ឯកឧត្តម ឧត្តមសេនីយ៍ឯក | **ហែម សុវត្ថិ** | អគ្គស្នងការរងនគរបាលជាតិ | សមាជិក |
| ១២- ឯកឧត្តម ឧត្តមសេនីយ៍ឯក | **ម៉ុនប៉ា ម៉ារីលុច** | អគ្គស្នងការរងនគរបាលជាតិ | សមាជិក |
| ១៣- ឯកឧត្តម ឧត្តមសេនីយ៍ឯក | **ស៊ាង ធារិទ្ធ** | អគ្គស្នងការរងនគរបាលជាតិ | សមាជិក |
| ១៤- ឯកឧត្តម ឧត្តមសេនីយ៍ឯក | **អ៊ុក ហៃសីឡា** | អគ្គនាយករងអន្តោប្រវេសន៍ | សមាជិក |
| ១៥- ឯកឧត្តម ឧត្តមសេនីយ៍ឯក | **កែម សារិន** | អគ្គនាយករងអន្តោប្រវេសន៍ | សមាជិក |
| ១៦- ឯកឧត្តម ឧត្តមសេនីយ៍ទោ | **លួ រ៉ាមូ** | អគ្គនាយករងអន្តោប្រវេសន៍ | សមាជិក |
| ១៧- ឯកឧត្តម ឧត្តមសេនីយ៍ឯក | **ស៊ូ សុផាន** | ប្រធានសេនាធិការដ្ឋាន | សមាជិក |
| ១៨- ឧត្តមសេនីយ៍ឯក | **ខ៊ែច ជួ** | ប្រធាននាយកដ្ឋាននគរបាលព្រហ្មទណ្ឌ | សមាជិក |
| ១៩- ឧត្តមសេនីយ៍ឯក | **ហ៊ីន សំណាង** | ប្រធាននាយកដ្ឋានចារកម្ម | សមាជិក |
| ២០- ឧត្តមសេនីយ៍ឯក | **សៀង សេន** | ប្រធាននាយកដ្ឋានប្រឆាំងបទល្មើសល្បែងពាណិជ្ជកម្ម | សមាជិក |
| ២១- ឧត្តមសេនីយ៍ឯក | **ធូ សារឿន** | ប្រធាននាយកដ្ឋានប្រឆាំងភេរវកម្មនិងឧក្រិដ្ឋកម្មឆ្លងដែន | សមាជិក |
| ២២- ឧត្តមសេនីយ៍ឯក | **សែម សុគាន់** | ប្រធានអង្គភាពអន្តរាគមន៍ | សមាជិក |
| ២៣- ឧត្តមសេនីយ៍ឯក | **ឃឹម សារ៉ាត់** | នាយកមន្ទីរប្រឆាំងគ្រឿងញៀន | សមាជិក |
| ២៤- ឧត្តមសេនីយ៍ឯក | **ឆន ឡាឌី** | ប្រធាននាយកដ្ឋានសន្តិសុខផ្ទៃក្នុង | សមាជិក |
| ២៥- ឧត្តមសេនីយ៍ឯក | **ឈុន ចាន់សុខា** | ប្រធាននាយកដ្ឋាននគរបាលបច្ចេកទេសវិទ្យាសាស្ត្រ | សមាជិក |
| ២៦- ឧត្តមសេនីយ៍ឯក | **យូ សារុំ** | ប្រធាននាយកដ្ឋានស៊ើបអង្កេតនិងអនុវត្តនីតិវិធីនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ | សមាជិក |
| ២៧- ឧត្តមសេនីយ៍ទោ | **សុខ នីត្យា** | ប្រធាននាយកដ្ឋានប្រឆាំងបទល្មើសបច្ចេកវិទ្យា | សមាជិក |
| ២៨- ឧត្តមសេនីយ៍ទោ | **ចាន់ សម្បត្តិ** | ប្រធាននាយកដ្ឋានសរុប ផែនការ | សមាជិក |
| ២៩- ឧត្តមសេនីយ៍ទោ | **សុក សំបូរ** | ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជន | សមាជិក |
| ៣០- ឧត្តមសេនីយ៍ទោ | **ប៉េង គង់** | អនុប្រធាននាយកដ្ឋានកណ្តាលសន្តិសុខ | សមាជិក |

៣១- **ស្នងការ នៃស្នងការដ្ឋាននគរបាលរាជធានី ខេត្ត** សមាជិក។

**ប្រការ២ ._**

គណៈបញ្ជាការដឹកនាំស្រាវជ្រាវ ស៊ើបអង្កេត និងបង្ក្រាបបទល្មើសគ្រប់ប្រភេទ មានភារកិច្ចដូចតទៅ៖

- ដឹកនាំការស្រាវជ្រាវ ប្រមូលផ្តុំ វិភាគ វាយតម្លៃសភាពការណ៍ ព័ត៌មាន និងបណ្តឹងនានាពាក់ព័ន្ធនឹងបទល្មើសព្រហ្មទណ្ឌគ្រប់ប្រភេទ រួមមាន៖ អំពើឃាតកម្ម អំពើបង្ខាំងមនុស្សជំរិតទារប្រាក់ អំពើបង្ខាំងមនុស្សធ្វើទារុណកម្ម បទល្មើសគ្រប់ទម្រង់នៃអំពើជួញដូរមនុស្ស ជួញដូរពលកម្ម និងអាជីវកម្មផ្លូវភេទ អំពើឆបោកគ្រប់ទម្រង់តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន បទល្មើសគ្រឿងញៀន ល្បែងស៊ីសងខុសច្បាប់គ្រប់ប្រភេទ និងបទល្មើសផ្សេងៗទៀតដែលជះឥទ្ធិពលជាអវិជ្ជមានដល់សង្គមជាតិ
- កំណត់គោលដៅអាទិភាព និងមុខសញ្ញាពាក់ព័ន្ធ ដើម្បីបើកប្រតិបត្តិការស្រាវជ្រាវ ស៊ើបអង្កេត និងបង្ក្រាបបទល្មើសព្រមទាំងកសាងសំណុំរឿងបញ្ជូនទៅតុលាការតាមនីតិវិធីជាធរមាន
- ចាត់បញ្ជូនក្រុមប្រតិបត្តិការជំនាញដែលត្រូវប្រចាំការអចិន្ត្រៃយ៍ ប្តូរវេន ឬចល័តផ្អែកតាមស្ថានភាពជាក់ស្តែង
- ចុះប្រតិបត្តិការ ស្រាវជ្រាវ ស៊ើបអង្កេត និងបង្ក្រាបដោយផ្ទាល់ដល់គោលដៅដែលត្រូវបានកំណត់អាទិភាព ឬ/និងគោលដៅដែលមានកើតឡើងនូវបទល្មើសជាក់ស្តែង
- សហការជាមួយស្ថាប័ន ឬអង្គភាពពាក់ព័ន្ធដើម្បីឱ្យកិច្ចប្រតិបត្តិការនេះ អនុវត្តស្របតាមនីតិវិធីជាធរមាន និងមានប្រសិទ្ធភាពខ្ពស់
- ទំនាក់ទំនង និងសម្របសម្រួល ដើម្បីសហការជាមួយយន្តការពាក់ព័ន្ធនានា នៅពេលរកឃើញថា គោលដៅ មុខសញ្ញា ឬ/និងករណីណាមួយមានការពាក់ព័ន្ធដល់ដែនសមត្ថកិច្ចនៃយន្តការដែលត្រូវទទួលបន្ទុក និងកំពុងដំណើរការ
- ចាត់តាំង និងណែនាំដល់ក្រុមបច្ចេកទេសវិទ្យាសាស្ត្រ ធ្វើការប្រមែប្រមូលកស្តុតាង រួមទាំងរូបភាព និងធ្វើកោសល្យវិច័យឱ្យបានត្រឹមត្រូវតាមឯកទេសវិជ្ជាជីវៈ ដើម្បីបម្រើឱ្យការងារជំនាញ និងនីតិវិធី
- ចាត់បញ្ជូនក្រុមអន្តរាគមន៍សម្រាប់គាំទ្រដល់ក្រុមប្រតិបត្តិការជំនាញ ក្នុងករណីចាំបាច់ ដើម្បីធ្វើឱ្យកិច្ចប្រតិបត្តិការបង្ក្រាបបទល្មើស ប្រកបដោយប្រសិទ្ធភាពខ្ពស់
- ពិនិត្យលទ្ធភាព និងលើកសំណើសុំបំពាក់មធ្យោបាយ ឧបករណ៍ សម្ភារបច្ចេកទេស និងថវិកា ដើម្បីលើកកម្ពស់សមត្ថភាព និងវិសាលភាពនៃកិច្ចប្រតិបត្តិការ
- រៀបចំក្រុមការងារបូកសរុប វាយតម្លៃ និងធ្វើការបំភ្លឺ បកស្រាយនូវព័ត៌មាននានាដល់ សាធារណជន និងប្រតិកម្មវាយបក ដើម្បីបន្សាបពល់ឥទ្ធិពលព័ត៌មានអវិជ្ជមាន ដែលធ្វើឱ្យប៉ះពាល់ដល់កិច្ចប្រតិបត្តិការ
- រៀបចំផែនការសកម្មភាពសម្រាប់កិច្ចប្រតិបត្តិការក្នុងការបង្ក្រាបបទល្មើស និងឧក្រិដ្ឋកម្មគ្រប់ប្រភេទ
- រាយការណ៍អំពីសភាពការណ៍ និងលទ្ធផលនៃកិច្ចប្រតិបត្តិការជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដើម្បីជូនជ្រាប និងសុំអនុសាសន៍ដឹកនាំបន្ត
- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

**ប្រការ៣ ._**

គណៈបញ្ជាការនេះ អាចរៀបចំបង្កើតក្រុមប្រតិបត្តិការជំនាញមួយចំនួនតាមការចាំបាច់ ដែលមានសមាសភាពនៅក្នុងប្រការ១ និងមកពីអង្គភាពមានសមត្ថកិច្ចពាក់ព័ន្ធ ដោយត្រូវបែងចែក និងប្រគល់ភារកិច្ចស្របតាមដែនសមត្ថកិច្ចជំនាញ ដើម្បីបំពេញភារកិច្ចប្រកបដោយប្រសិទ្ធភាព។

**ប្រការ៤ ._**

គណៈបញ្ជាការនេះ អាចចេញសេចក្តីណែនាំ អំពីរបៀបរបបបំពេញការងារ និងទំនាក់ទំនងសហការរវាងអង្គភាពជំនាញពាក់ព័ន្ធ ដើម្បីធ្វើឱ្យកិច្ចប្រតិបត្តិការនានាប្រព្រឹត្តទៅដោយរលូន និងស្របតាមនីតិវិធីជាធរមាន។

**ប្រការ៥ ._**

អនុប្រធាននិងសមាជិកនៃគណៈបញ្ជាការត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានគណៈបញ្ជាការ។

អនុប្រធាន និងសមាជិកនៃគណៈបញ្ជាការ ត្រូវទទួលអនុវត្តភារកិច្ចតាមការចាត់តាំងរបស់ប្រធានគណៈបញ្ជាការ។

គណៈបញ្ជាការនេះ អាចប្រើប្រាស់មន្ត្រីក្រោមឱវាទ ដើម្បីបំពេញភារកិច្ច។

**ប្រការ៦ ._**

គណៈបញ្ជាការនេះ អាចប្រើប្រាស់ត្រារបស់អគ្គស្នងការដ្ឋាននគរបាលជាតិ ក្នុងការបំពេញភារកិច្ច។

**ប្រការ៧ ._**

អភិបាល នៃគណៈអភិបាលរាជធានី ខេត្ត ត្រូវចាត់អភិបាលរងទទួលបន្ទុកការងារសន្តិសុខ ដើម្បីសហការ សម្របសម្រួលនិងគាំទ្រដល់ក្រុមជំនាញ នៅពេលមានកិច្ចប្រតិបត្តិការក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

**ប្រការ៨ ._**

គណៈបញ្ជាការដឹកនាំស្រាវជ្រាវ ស៊ើបអង្កេត និងបង្ក្រាបបទល្មើសព្រហ្មទណ្ឌគ្រប់ប្រភេទ ត្រូវបើកកិច្ចប្រតិបត្តិការដែលបានកំណត់ក្នុងសេចក្តីសម្រេចនេះ ក្នុងភូមិសាស្ត្ររាជធានីភ្នំពេញដើម្បីជាបទពិសោធន៍ឈានទៅអនុវត្តក្នុងក្របខ័ណ្ឌទូទាំងប្រទេស។

**ប្រការ៩ ._**

បទប្បញ្ញត្តិទាំងឡាយណាដែល ផ្ទុយនឹងសេចក្តីសម្រេចនេះត្រូវទុកជានិរាករណ៍។

**ប្រការ១០ ._**

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គស្នងការនៃអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល អគ្គនាយកនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ អគ្គនាយកនៃអគ្គនាយកដ្ឋានភស្តុភារនិងហិរញ្ញវត្ថុ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ស្នងការនៃស្នងការដ្ឋាននគរបាលរាជធានី ខេត្ត ប្រធាននាយកដ្ឋាន-អង្គភាពពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ៕

ថ្ងៃព្រហស្បតិ៍ ១៤ រោច ខែអស្សុជ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**អភិសន្តិបណ្ឌិត ស សុខា**

<u>កន្លែងទទួល:</u>

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមអភិសន្តិបណ្ឌិត ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ១០
- ឯកសារ កាលប្បវត្តិ